«សង្សារខ្ញុំ! ម៉េច? អស់ចិត្តឬនៅ? »

ថាហើយនាងដោះកន្ត្រកបោះចុះដីហើយចាប់ផ្ដើមរើកាំបិតចេញមកជីកគាស់។ ស្រីស្អាតជីកដើមរុក្ខជាតិមកព្យាបាលឱ្យនាយ មិនទាំងចាប់អារម្មណ៍ឡើយថាពាក្យចុងក្រោយរបស់ខ្លួនឯងធ្វើឱ្យអ្នកប្រុសឆ្ងាយសំណើច។

គេក្រពាត់ដៃគ្រវីក្បាលព្រោះអស់ពាក្យនិយាយ ដឹងអីកគ្រេចបន្តឈឺធ្វើមុខជូរសើចលែងសម។

នាងបានរុក្ខជាតិកាលណារើដបទឹកក្រហមត្លៃ និងត្បាល់បុកមួយចេញពីក្នុងកន្ត្រក។

មិននឹកស្មានថា នាងលើករបស់ច្រើនយ៉ាងនេះធ្ងន់យ៉ាងនេះហើយដើរមកបានឆ្ងាយយ៉ាងនេះមិនត្អូញត្អែរអ្វីថែមទាំងត្រូវខ្លួនស្ដីថាឱ្យទៀត?

មើលរាងនាងដែលអង្គុយចិញ្ច្រាំថ្នាំដាក់ត្បាល់គួរឱ្យអាណិត ។ អាណិកជនភ្លេចអស់ការទើសទ័លនិងសម្ដីផងទាំងឡាយក៏ចូលទៅក្បែរហើយអង្គុយចុះជិតនាង។

នាងព្មដង្ហើមនាយតែនាងធ្វើហីមិនខ្វីនិយាយ មិនខ្វីងាក ចាប់ផ្ដើមបុកពួករុក្ខជាតិបញ្ចូលគ្នា។

«សុំទោសបានអត់?»

«មនុស្សខ្ញុំមិនចេះខឹងទេ!»

នាងឆ្លើយយ៉ាងរត់មាត់តែមុខនាងខឹងច្បាស់ក្រឡៃត។

«Lorenzoតារាសប្បុរសល្បីនៅភ្នំពេញហ្នឹងមែនអត់ជាសង្សារខ្លួនឯង!»

គេនឹកឃើញនិយាយលេងបន្លប់បរិយាកាសគ្រោតគ្រាត មិនស្មានដល់ទេថា ឈ្មោះបីម៉ាត់នេះអាចនាំនាងឱ្យសើចវិញបានសោះ។ ស្រីតូចញញឹមចិញ្ចាចបញ្ចេញសម្រស់ត្រដែតជាមួយធ្មេញទាំងជួរសដូចម្លិះ។

«ស្គាល់គាត់ដែរ?»

នាងងាកមកនិយាយភ្លាមៗធ្វើឱ្យប្រុសស្អាតភ័ន្តភាំង។ គេនៅទ្រឹងសម្លឹងប្រតិកម្មពេញដោយភាពរំភើបលើផ្ទៃមុខដែលមានទម្រង់ទ្រវែង ហ្មត់ហ្មង់គ្មានសូម្បីស្នាមផុររមាស់អ្វីមួយ។

សក់នារីនេះវែងអន្លាយខ្មៅរលោងរលាស់ពេញដោយជីវិតជីវា ហើយចុងសក់ប៉ប្រះថ្ពាល់នាង ក៏បក់រវិចចុះឡើងទៅតាមកិរិយាជ្រួលច្របល់នៃម្ចាស់វា។

គេទ្រាំមិនបាននឹងអាការៈស្រីតូចនេះ ក៏សួរបកទៅវិញទាំងជ្រួញចិញ្ចើម៖

«ហើយមានទំនាក់ទំនងអីនឹងម្នាក់នោះ?»

«ខ្ញុំសួរថាបងឯងម៉េចបានស្គាល់គាត់!»

គេចាប់ផ្ដើមងាកមកប្រយ័ត្នសមាសភាពខ្លួនឡើងវិញ ហើយរកពាក្យនិយាយបង្វែងឆ្ងាយពីប្រភពពិតរបស់ខ្លួន៖

«កាលនៅលើទូក ពួកកម្មកររនេសាទជាមួយគ្នាគេធ្លាប់និយាយឱ្យស្ដាប់ថាម្នាក់នោះជាអ្នកមានល្បីនៅភ្នំពេញ!»

នាងឮថានាយជាកម្មករក៏ឈប់ដៃ ឆ្លោយសម្លឹងពិនិត្យនាយយើងសាជាថ្មីពីលើចុះក្រោម ធ្វើឱ្យទេវបុត្រសេះស រឹតតែបានចិត្តនិយាយកុហកបន្ថែមរដូចទឹក៖

«បងឯណាដែលបានទៅភ្នំពេញ? មិនដឹងទីក្រុងបែរទៅណាផង! មួយជីវិតនេះដើរតែធ្វើការ ឱ្យគេលើទូក!»

នាងជ្រួញចិញ្ចើមនិយាយ៖

«អ៊ីចឹងបានដៃជើងបងឯងមើលទៅមនុស្សលំបាកហ្មងហ្នឹង!»

ស្រីស្អាតនេះព្យាយាមធ្វើចរិតដូចជាខ្លួនឯងជាមនុស្សឆ្លាត Lorenzoដឹងអ៊ីចឹងបានជានាយមិនខ្វីប្រកាន់ខឹង។ នៅតែបន្តិចទៀតនាងអាចនឹងដូរពីពាក្យ «លំបាក» មកជា «ក្រ» តែម្ដងក៏ថាបានមនុស្សមាត់ដាចដូចនាង។

មុននេះនាងទាយថាគេជាអ្នកភ្នំពេញ ពេលនេះឮប្រវត្តិជាកម្មករក៏និយាយចាក់បណ្ដោយខ្លាចគេថាខ្លួនមិនពូកែសង្កេតមើល។

បុរសញញឹម ភ្លេចការឈឺចាប់។

លើលោកនេះមនុស្សស្រីគេជួបច្រើនហើយ។ នារីអភិជន មិនថាឆ្នាំនាគ ឬមិនមែន ឱ្យតែគេប៉ងសុទ្ធតែបានអង្គុយទល់មុខក្រោមភ្លើងទានជាមួយគ្នាម្នាក់ៗញញឹមញញែមយកចិត្តគេ មិនសមថាពេលនេះមកអង្គុយកណ្ដាលផ្លូវកណ្ដាលព្រៃក្លែងខ្លួនជាអ្នកនេសាទកម្សត់ឱ្យស្រីច្រមក់ម្នាក់មើលងាយកាយសម្បទារបស់គេសោះ។

«ហើយបងLorenzoរបស់ខ្លួនឯង ស្អាតសង្ហាប៉ុនណាទៅអ្ហះ?»

គេខ្សឹបសួរពេលដៃនាងតូចកំពុងបុកថ្នាំប៉ូកៗ ហើយបបូរមាត់នាងញញឹម ពណ៌ក្រពុំឈូក។

«មិនដែលឃើញមុខទេ ឮតែឈ្មោះគាត់!»

នាងឆ្លើយធ្វើហីហើយបុកថ្នាំបន្ត។ បុរសអាណិកជនយល់ថានាងតូចនេះអាល័យតែមានអារម្មណ៍ខ្លាំងពេលនិយាយរំលឹកអំពីឈ្មោះរបស់អ្នកមាននៅឯទីក្រុង ទើបមិនបានមកនឹកខ្វល់សូម្បីតែនឹងសួរថា កម្មករនេសាទម្នាក់នេះធ្វើដូចម្ដេចក៏រសាត់អណ្ដែតមកដល់ទីនេះ?

គេឃើញនារីតូចនេះលាយល្បាយជាច្រើនបញ្ចូលគ្នា ខ្លះជាវត្ថុរាវខ្លះជាម្សៅហើយខ្លះទៀតជារុក្ខជាតិដែលនាងទើបនឹងជីកបាន។ ទោះយ៉ាងណាពេលនេះអាណិកជន ចាប់អារម្មណ៍ខ្ពស់តែអំពី រឿងថានាងហេតុអ្វីស្គាល់ឈ្មោះខ្លួនហើយអួតខ្លួនជាសង្សារទាំងដែលមិនធ្លាប់ឃើញមុខគ្នាម្ដងសោះ។

«មានសង្សារមិនឃើញមុខគ្នាដែរ? ខ្លួនឯងដឹងថាសង្សារគេសំដៅលើអីអត់?»

ម្ដងៗគេសឹងតែច្រឡំប្រើពាក្យនៅអាមេរិក ហើយចង់និយាយថា នៅលោកខាងលិចគឺពាក្យសង្សារគេសំដៅលើមនុស្សបានគេងជាមួយគ្នា ដោះដូរខ្លួនប្រាណជាមួយគ្នាដែលនាងមិនសមយកមកប្រើស្ដួយៗបែបនេះទេ។ ចំណែកនាងមើលទៅដូចកុលាបក្នុងទងក្រពុំ សូម្បីតែរីកក៏មិនទាន់រីកគ្រប់ស្រទាប់ផង។

ប្រុសម្នាក់នេះរេភ្នែកលួចពិនិត្យរាងកាយនាងពីលើដល់ក្រោម។ ក្រៅពីដើមទ្រូងពើងខ្ពស់ជំទើតលាក់ក្នុងអាវរបស់នាង សន្យាថែមទាំងអង្គុយខ្ទែតចង្កេះជាមួយត្រគាករីកសាយ។ បុរសអភិជនស្រមៃនឹកឃើញ ប្រសិននាងបែរជាស្ថិតក្នុងលំដាប់អាវរាត្រីម៉ាក Natori អ្វីទាំងពួងនោះវិញ ពួកអភិជនស្រីៗដែលបានណាត់ជួបអាចថាគ្មានអ្វីលើសស្រីច្រមក់នេះផងក៏ថាបាន។

នាងនិយាយចច្រែតមិនមានរវល់នឹងកែវភ្នែកបុរសសម្បូរស្នេហ៍៖

«ខ្ញុំកុហកក៏បងឯងជឿដែរ?»

គេហួសចិត្តដែលនាងគិតថាគេព្រមជឿ។ ទោះយ៉ាងណាក៏ដោយ សម្ដែងល្ខោនគួរតែសម្ដែងឱ្យចប់ចុងចប់ដើម។

«ចុះមុននេះ អ្នកណាថាបន់ស្រន់ ឱ្យជួបគេ?»

សន្យាឆ្លើយតបទាំងមិនបានងើបមុខមកសម្លឹងនាយ៖

«ខ្ញុំកំពុងចង់ជួបគេដើម្បីសុំជំនួយ!»

នឹកដល់រឿងជំនួយ បុរសអ្នកមានធ្វើមុខស្មើ។ ចរិតរបស់គេមិនចូលចិត្តស្រាប់ហើយពួកមនុស្សដែលស្រេបស្រាលនឹងការមានបានហើយរស់នៅរំពឹងតែលើការហុចដៃសុំជំនួយអំពីអ្នកដទៃ។

គេស្តីបន្ទោសភ្លាម៖

«មានដៃពីរជើងពីរ មិនចេះធ្វើការចេះតែសុំគេ !»

នារីតូចងើបមុខមកវិញសម្លក់នាយហើយនិយាយផ្ទូង៖

«អ៊ីចឹងបងឯងសន្យាភ្លាមមក ថាឱ្យតែជាកាលណា ត្រូវនៅហ្នឹង ជួយជីកអណ្តូងទឹកឱ្យខ្ញុំឱ្យបាន៧៨អណ្តូង!»

គេបើកភ្នែកធំៗ។

នាងធ្វើរញ៉ាំរញ៉ូវទាញអាវនាយដោះធ្វើឱ្យនាយភ័ន្តភាំងប្រកែករាដៃ។

«អ្នកស្រុកនេះគេខឹងម្តងៗរ៉ែដោះអាវហ្មែន?»

សន្យាគក់បុរសនេះ ផាច់ៗ ទាំងដែលគ្នានៅសើចតាមសម្លឹងមើលកណ្តាប់ដៃនាង។

«មនុស្សកំពុងគ្រេចក!»

គេនិយាយទាំងសើចក្អាកក្អាយ។

«បើមិនដោះអាវលាបថ្នាំម៉េចអាឡូវ?»

ទេវបុត្រញញឹមនៅសំងំស្ងៀមឱ្យបុប្ផាជាយព្រៃ ដោះអាវគេម្ខាងទម្លាក់សំយេះចេញហើយបណ្តោយឱ្យនាងយកល្បាយដែលបុកហើយសើមស្អិតនោះមកប៉ាត់លាបដោយម្រាមនាងផ្ទាល់លើកញ្ចឹងកនិងស្មាឆ្វេង។

ស្រីស្អាតនៅស្ងាត់ស្ងៀមតែគេដឹងថានាងកំពុងប្រឹងធ្វើទាំងអៀនប្រៀននឹងរាងកាយជាប្រុសស្អាតរបស់ខ្លួនបានជានៅស្ងាត់មាត់ដូច្នោះ។

គេចាប់ផ្តើមបានចិត្តនិយាយចំអន់៖

«បើបងកម្មករម្នាក់នេះនិងអាម្នាក់ Lorenzo នោះមកឈរទន្ទឹមគ្នាឱ្យរើស ខ្លួនឯងរើសយកមួយណាអ៊ុំគ្រូពេទ្យ?»

នាងអាចមើលឃើញស្នាមញញឹមស្រស់បំព្រងរបស់បុរសនេះជាលើកដំបូង ព្រោះកាលពីយប់រហូតដល់ភ្លឺក្រៅពីតម្កើងឫកធ្វើដូចអ្នកអង្គម្ចាស់ គេមិនបានឱ្យនាងសូម្បីតែកែវភ្នែកស្រទន់មួយក្រឡេក កុំថាដល់ទៅញញឹមបង្អួតភាពជាបុរសរបស់គេដូចក្នុងពេលនេះ។

ទោះយ៉ាងណាពេលមានអារម្មណ៍កាន់តែចាញ់ប្រៀបលើរូបសម្រស់គេ នាងក៏កាន់តែចេះប្រុងប្រយ័ត្នក្រែងភ្លាត់ឱ្យគេដឹងចិត្តខ្លួនដែលកំពុងគិតអ្វីចំពោះចំហាយស្នេហ៍នៃភាពជាបុរសពេញលក្ខណៈរបស់គេ។

តូចតន់ឆ្លើយបន្ទន់សំឡេងតែពង្វាងអត្ថន័យ៖

«អ្នកណាក៏ដោយ ឱ្យតែមានអណ្តូងឱ្យ៧៨!»

«ស្អីគេ យកមកធ្វើអីច្រើនម្លេះ?»

«ខ្ញុំដឹងអ្នកនិយាយហ្នឹងគ្មានលុយហើយ!!! តែមិញអ្នកណាអួតថាមានដៃពីរមិនបាច់សុំគេ! ចាំមើលអ្នកពូកែហ្នឹងជីកបានប៉ុន្មានអណ្តូង?»

បុរសញញឹម នាងឱនទៅលើកយកកម្ទេចដៃអាវគេដែលរហែកទើរលើមែកឈើកាលពីយប់មករុំរបួសព័ទ្ធទៅក្រោយឱ្យហាក់ស្ទាត់ជំនាញ។

«ហើយរត់ទៅកន្លែងហ្នឹងយកអាវរហែកមកវិញបានទៀត?»

នាងនៅចងអាវមុខស្មើមិននិយាយមិនឱ្យគេចាប់ថ្នាក់ការកម្រើកនៃបេះដូងបានទេ។

ឯខាងបុរសគិតពីញ៉ោះមិនឈប់៖

«យប់ងងឹតនៅហ៊ានទៅទៀត ហ៊ានណាស់ហ្ន៎អត់ខ្លាចទេ!»

«រឿងដែលខ្លួនមិនដឹងមានច្រើនជាងហ្នឹងទៀត! »

ស្រីតូចប្តូរពីពាក្យបងមកជា«ខ្លួន»គឺនាងនិយាយតាមពាក្យគេ ដែលហៅនាងដូច្នេះ។ ក្នុងការសង្កេតរបស់Lorenzo នារីនេះចម្លងគេបានយ៉ាងរហ័សដូចម៉ាស៊ីនកុំព្យូទ័រ នាងពិតជាមានភាពវៃឆ្លាតតែហេតុអ្វីបានជានាងមានជីវិតរបស់នាងនៅអាថ៌កំបាំងហើយស្ងប់ស្ងាត់បែបនេះ?

គេគិតម្នាក់ឯងក្នុងចិត្ត.....

រាត្រីកាលវិលមកវិញ នៅតំបន់ភ្នំពោរពេញទៅដោយសន្សើមត្រជាក់។ នេះគឺជាយប់ទីពីរដែលអភិជនត្រូវសម្រាកក្នុងផ្ទះអនាគត។

គេចូលមកដល់ទីសម្រាកក៏ឃើញនាងរៀបចំដាក់ចំបើងក្រាសឃ្មឹកហើយក្រាលភួយពីលើនៅឯគ្រែឈើដ៏តូចប្រែខ្លួនសឹងមិនចង់បានមួយនោះ។

ធុញណាស់និងបរិយាកាសនេះ ប៉ុន្តែងាកមកឃើញរង្វង់មុខតូចច្រឡឹងរបស់នាងដែលខំរៀបចំកន្លែងឱ្យខ្លួនបែកញើសសស្រោក់ទាំងអាកាសធាតុត្រជាក់ បុរសនេះមិនអាចធ្វើចិត្តថ្មបាន។

គេសួរទាំងឈរផ្ទឹង៖

«ក្រាលចំបើងធ្វើអី?»

នាងសម្លក់ហើយនិយាយផ្ទូង៖

«ស្មានថាក្រាលឱ្យគោស៊ី?»

គេឃើញនាងសម្លក់ក៏ញញឹមតប។

ស្នាមញញឹមបុរសនេះរឹតតែចិញ្ចាចក្រោមស្រមោលព្រះចន្ទនាយប់១៤កើត។ នាងពិតជាអៀនតែក៏កក់ក្ដៅនិងរូបសម្រស់របស់ទេវបុត្រ។ ប្រសិនបើគេមានវត្តមាននៅផ្ទះអនាគតកាន់តែយូរ នាងមុខតែនឹងអរគុណព្រះជាក់ជាមិនខាន។

គេនិយាយពេលឃើញនាងលាក់លៀមក្ដីអៀនប្រៀន៖

«ស្មានថា អ្នកណារៀបការ ហើយចាប់ក្មេងៗឱ្យរៀបចំគ្រែផ្សំដំណេកឱ្យ!»

«ខ្ញុំកើតឆ្នាំ២០០០ មិនមែនក្មេងទេ! បងឯងរាប់សាដើមទៅ!»

ប្រុសស្អាតរុះរោយស្នាមញញឹមសន្សឹមៗ។ ពាក្យឆ្នាំ២០០០បានធ្វើឱ្យក្ដីឈឺចាប់ក្នុងបេះដូងរើឡើងមកវិញ ហើយគេនឹកឃើញដល់កូននាគីស្រស់ៗរបស់ត្រកូលអភិជនផងទាំងពួងដែលខ្លួនបានជំពាក់ភ្នែក។ ពួកគេពេលនេះមិនដឹងជាយ៉ាងណាហើយទេ គម្រោងការទាំងអស់ក៏កំពុងតែក្លាយជាផេះដែរ។

«អូយឈប់ហៅបងក៏បាន! ដុះពុកមាត់តិចតួចមិនមែនមានន័យថាធំជាងខ្ញុំប៉ុន្មានទេ! ប្រាប់ឈ្មោះមក ហៅឈ្មោះហ្មងបានស្មើគ្នា!»

នាងនិយាយរញ៉ាំរញ៉ូវបន្តបន្ទាប់គ្នា តែទេវបុត្រដឹងថា កូននាគកម្សត់នេះ និយាយឱ្យតែបាននិយាយបន្លប់ភាពរំភើបដែលបេះដូងនាងកំពុងលោតចម្រប់ធ្លាក់លង់ក្នុងអន្លង់មន្តស្នេហ៍ប្រុសស្អាតនៅនឹងមុខនេះទៅហើយ។

Lorenzo នៅជិតនារីនេះ ភ្លេចអស់ទុក្ខកង្វល់។ គេញញឹមដើរទៅពីក្រោយនាងហើយលូកដៃម្ខាងដែលមិនឈឺ ទៅចាប់ស្មា។ បុប្ផាព្រឹក្សព្រៃ នៅទ្រឹងបន្តិចដែរពេលត្រូវគេប៉ះបន្ទាប់មកក៏រេខ្លួនទម្លាក់ដៃគេចេញ។

ពេលសន្យាងាកមកសម្លក់ ភ្នែកស្រីទាំងសង ហាក់ធំប្រដែងទំហំ ពងមាន់។ ជាមួយអំពូលម៉ាងសុងក្រហមរស្មីមាស នាងពិតជាស្អាតដូចសត្វក្ងោកលាក់កន្ទុយមិនទាន់បញ្ចេញ។ រោមភ្នែកងរខ្វង់ហើយប្រស្រីភ្នែកធំៗដូចគេបង្កប់ត្បូងនិលនៅខាងក្នុង។ ភាពស្មោះបរិសុទ្ធនៅក្នុងពន្លឺភ្នែកនាង និងបបូរមាត់រីកត្រសុំដូចបុប្ផារីកគ្រប់រដូវ ធ្វើឱ្យបុរសមើលភ្លឹក។ តណ្ហានៃការចង់បានថ្កាមកឱបប្រលោមកម្រើករំពើកក្នុងទ្រូងមនុស្សប្រុសឡូយឆាយដែលធ្លាប់ឆ្លងកាត់រាត្រីជាមួយមនុស្សស្រីរាប់មិនអស់។

ក្មេងស្រីមិនទាន់ជ្រុះពន្លៃពីក្បាលដូចនាង បេះដូងគ្មានកករល្អក់ដូចនាង តើរសស្នេហ៍ផ្អែមដូចទឹកឃ្មុំដែលរកបានពីអាម៉ាហ្សូន ព្រៃដ៏កម្រនោះដែរឬអត់ទេ?

«ប៉ះពាល់ខ្លួនគេពេញមួយតួ! ពេលនេះកាន់ស្មាតិចតួច ធ្វើឯងរលាស់ចេញ!»

សំឡេងគេនេះប្តូរមកជាលែងទ្រគោះ ខ្ពស់កប់ពពកដូចពីម្សិល ហើយវាមានសព្ទពីរោះ ពិសាបន្ទន់ចិត្ត។

សន្យារេភ្នែកចេញពីពន្លឺចក្ខុគេ ព្រោះនាងមិនចង់ឱ្យគេឃើញមូលហេតុដែលធ្វើឱ្យដង្ហើមនាងដកញាប់។ ភាសាបេះដូងមិនអាចលាក់តាមសរសៃភ្នែកបានឡើយ។ ស្រីតូចសម្លឹងមកស្មាហើយទ្រូងនិងទម្លាក់ពីចង្កេះមកដល់ចុងជើងគេ។

ធម្មតានាងពូកែនិយាយបំផុត តែពេលនេះដូចជាកំពុងស្ងាត់ឈឹង។

កម្មករនេសាទម្នាក់នេះ មន្តស្នេហ៍រាលរាលពេកហើយ នាងគិតម្នាក់ឯងស្របពេលដែល ស្រមោលគេក៏រំកិលចូលមកក្បែរ ធ្វើឱ្យនាងដកថយ។ នាងកាន់តែដកថយ គេកាន់ចង់បន្ថែមទៅមុខ។

«ខ្ញុំហៅបងឯងថាពូវែងចុះ!»

គេទ្រឹងលែងចូលទៀតព្រោះអាណិតនាងដែលនៅតែខំបន្តប់ចិត្តស្រលាញ់។ នាងទាបស្រាប់ហើយកំពុងអៀន ឈ្ងោកមុខក្រោមទ្រូងបុរសនេះ។

គេដឹងថាកម្ពស់ខ្លួនឯងទេ ដែលធ្វើឱ្យកូននាគច្រឡឹង មកដាក់ឈ្មោះ «វែង» នេះឱ្យគេ។ ប្រុសស្អាតប្រើសំឡេងស្រទន់សួរ៖

«អស់ពីបង មកហៅពូឱ្យចាស់គ្នាអស់!»

នាងឆ្លើយផ្លូងទាំងសើចខឹក៖

«អ៊ីចឹងហៅអាវែង?»

នាងសើចខឹកៗង៉ើយសម្លឹងនាយដែលមិនខ្វីសើច។

បុរសនេះក្តាប់មាត់ប្រឆាំងនិងរាងកាយដែលចង់រឹតត្បិតឃុំឃាំងកូននាគច្រឡឹមឱ្យជាប់រហូតដល់នាងស្រែកអង្វរចាំលែង តែគេទប់ចិត្តបាន ព្រោះទងផ្កាមិនសមណាឱ្យបុរសណាម្នាក់មកធ្វើបាបប្រឡាក់ប្រឡូសទឹកចិត្តដ៏ល្អបរិសុទ្ធរបស់នាងទាល់តែសោះ។

គេប្តូរពីរចង់ក្រសោប មកប្រើដៃដដែលក្តាប់ស្មានាង។

«ហៅម្តងទៀតមើល៍!»

បុរសនិយាយទាំងខាំមាត់។ នាងរលាស់ចេញ គេមិនលែង នាងកាន់តែរើគេកាន់តែកាន់ជាប់ម៉ឹង។ នាងធ្វើមុខជូរស្រែកដាក់៖

«គេមានកម្លាំងគេហើយហ្មែន! ដឹងអ៊ីចឹងយប់មិញទុកឱ្យដេកក្តៅមិនខ្វីស្ពំទឹកឱ្យទេ! អត់ងងុយឡើងមួយយប់ទល់ភ្លឺ!»

ម្រាមនាយរបូតខ្សាក ព្រោះតែការទោរទន់ដូចបាយម៉ាននៃចិត្តដែលជាអភិជនរឹងរូសក្រអឺតក្រអោង។ កាលពីមុន មនុស្សស្រីកើតឆ្នាំ២០០០ក៏ដោយ បើមិនមែនអ្នកនាងធំអ្នកនាងតូចកុំសង្ឃឹមLorenzoនឹងយកខួរទៅគិត។ ពេលនេះគេធ្លាក់ខ្លួនលង់អាណិតកូននាគតូចល្អិតយ៉ាងជ្រៅ មិនដែលមានមកពីមុនជាមួយស្រីឯណាដូច្នេះឡើយ។

«ហើយអត់គេងមែន?»

គេសួរតិចៗដោយខ្សែភ្នែកស្រទន់ ។

នាងងាកមុខចេញហើយនិយាយ៖

«រកធ្មេច អ្នកខ្លះស្រែកក្ដៅ មមើមមាយ! ធ្មេចម៉េចនឹងលក់!»

នាងចាកចេញទុកឱ្យនាយឈរម្នាក់ឯងក្នុងខ្ទម។ មនុស្សមិនដែលស្គាល់គ្នា ម្ដេចក៏នាងមកយកចិត្តទុកដាក់រឿងអាយុជីវិតនាយធ្វើអ្វី? បុរសថយទៅអង្គុយគិតលើគ្រែក៏ឃើញនាងលើកល្អីមួយចូលមកនាំទាំងក្លិនឆៃថាវមកជាមួយ។

គេជ្រួញចិញ្ចើមនិយាយ៖

«យកស្អីចូលមកហ្នឹង ធំក្លិនអាក្រក់!»

នាងសម្លក់នាយដូចមុនហើយទើបនិយាយ៖

«កន្លែងនេះរោងបាយ បើមិនយកឆៃប៉ូវមកទុក ឱ្យទុកនៅឯណា? ថ្នាក់រៀនអត់ទ្វារទេ បើកណ្ដុរមកស៊ីអស់ ស្អែកក្មេងៗបានអីហូបបបរ?»

«ក្មេងៗណា?»

«កូនសិស្សរបស់សាលាអនាគត!»

គេលបសម្លឹងនាងពីក្រោយ។ គេយល់ហើយថាទីនេះជាសាលាសម្រាប់ពួកក្មេងក្រីក្រ ហើយក៏យល់បណ្ដើរៗដែរថា ហេតុអ្វីបានជានាងចង់ជួប Lorenzo។

«បងឯងគេងទៅ! ស្អែកហ្នឹងក្មេងៗមកតាំងងងឹតឡូឡាពេញហ្នឹង! តិចថាគេងមិនគ្រប់ លាប់គ្រុនវិញ!»

គេសម្លឹងជុំវិញខ្លួនសាជាថ្មី។ អាការៈកនិងសរសៃគ្រេចហាក់ដូចធូរស្រាលស្មើទិព្វមន្ត ឱសថអីក៏សក្ដិសិទ្ធិម្ល៉េះ? ដោយសារតែយ៉ាងនេះ ទើបពួកអ្នកស្រុកអាចរស់នៅទីដាច់ស្រយាលអស់ទាំងនេះបាន?

គេរវេភ្នែកពិនិត្យថានផ្ទាំងដែលបីពេលមកហើយ គេស្គាល់តែអំបិលនិងបបរក្ដៅ នាងគ្មានអាហារ ឬជំងឺគេមិនអាចឆីអ្វីផ្សេងបាន?

គេសួរស្រាលៗ៖

«គ្មានត្រីសាច់ទេ មានតែឆែថាវក្រៀមអស់នេះ?»

នាងនៅស្ងៀមទ្រឹងដៃឈប់រៀបចំរបស់របរមុនពេលងាកមកយឺតៗ។ សេចក្តីអាណិតអាសូរកើតមានក្នុងកែវភ្នែកនារីនេះ។ នាងដើរចូលមកក្បែរហើយទាញកៅអីអង្គុយទល់មុខនាយដូចកាលពីព្រឹក។

«បងឯងឃ្លានហ្មែន?»

គេនៅស្ងៀមលង់ក្រោមចិត្តមេត្តារបស់នាង។ ប្រុសស្អាតមិនឆ្លើយរវល់តែសម្លឹងកែវភ្នែកនាងទាំងសងខាងធ្វើឱ្យស្រីតូចសន្សា លាន់មាត់មកទៀត៖

«បងឯងហ៊ាននៅតែឯងអត់? ខ្ញុំជិះទៅភូមិទិញសាច់ និងត្រីមក!»

គេមិនឆ្លើយបែរជាប្រើដៃដែលមិនឈឺទាញប្រអប់ដៃនាងឱ្យក្រោកមកជាមួយ។

«មិនឃ្លានអីទាំងអស់! ចង់អង្គុយមើលលោកខែនិយាយគ្នាលេងមួយកូននាគ!»

នាងបណ្តោយឱ្យប្រុសស្អាតបណ្តើរមកក្រៅ ព្រោះអាល័យតែភ្លឹកនិងពាក្យ «កូននាគ»ដែលគេទើបនឹងហៅ។

បុរសឈរវំភើយស្រូបយកខ្យល់អាកាសហាក់រីករាយនឹងវិស្សមកាលមួយមិនបានព្រាងទុកនេះ ស្រាប់តែឮនាងសួរផ្ទូង៖

«ម៉េចបងឯងដឹងថាគេកើតឆ្នាំនាគ!»

ប្រុសស្អាតងាកមកវិញទាំងបើកភ្នែកធំៗ ហើយឆ្លើយតបវិញហាក់ហួសចិត្ត៖

«អុញ! អ្នកណាប្រាប់ថាខ្លួនឯងកើតឆ្នាំ២០០០?»

នាងបូញមាត់រអ៊ូ៖

«គិតលេខរហ័សម៉េះ? ចេះរាប់ឆ្នាំខែទៀត? កម្មករសមុទ្រសោះហ្នឹង!?»

បុរសក្រឡេកមកនាងជាមួយខ្សែភ្នែកស្រទន់ជាងពន្លឺព្រះចន្ទដែលចាំងពីលើក្បាលពួកគេទាំងគូនេះទៅទៀត។ កម្មករសមុទ្រអាចធ្វើឱ្យស្រីចិត្តបរិសុទ្ធមានមេត្តាករុណាលើគេកម្រិតនេះ យើងគួរសំងំធ្វើជាកម្មករនេសាទតទៅ ឬមួយសារភាពពីអង្គLorenzoក្នុងខ្លួនយើងប្រាប់ដល់នាងជាការស្មោះត្រង់ទៅវិញទៅមក?

នាងថយទៅអង្គុយលើគ្រែឫស្សីធំមួយ ជាកន្លែងទុកសម្រាប់ឱ្យពួកក្មេងៗហូបអាហារនៅសំយាបខាងក្រៅថ្នាក់។ បុរសថយទៅអង្គុយក្បែរ ហើយរេភ្នែកសម្លឹងចូលទៅខាងក្នុងថ្នាក់ដែលងងឹតស្រពេចស្រពិលពឹងលើភាគរយខ្លះដែលបានពន្លឺដោយសារស្មៃព្រះចន្ទ្រារះ ជះចាំងមកដល់។

«នេះហ្អីថ្នាក់រៀន?»

គេសួរ ទាំងគិតជាស្រេចដល់ការសាងសាលាមួយសម្រាប់ផ្ទះអនាគតរបស់កូននាគ។

ស្រីតូចមិនឆ្លើយអ្វី បុរសនេះក៏ថាបន្តទៀត៖

«ហើយរាល់យប់មកគេងនៅហ្នឹង? គេងហិតក្លិនពួកឆែថាវក្រៀមអស់ហ្នឹង!»

«ឆែប៉ូវអត់ស្គាល់ឆែប៉ូវទេអី?»

គេងៀងមើលនាងហើយលូកដៃទៅកាន់ដៃសាជាថ្មី។ នាងដកចេញយឺតៗហើយនិយាយតប៖

«បើគ្មានអ្នករបួស គ្មានអ្នកណាគេមកគេងនៅហ្នឹងទេ!»

បុរសញញឹម។

សេចក្ដីអំណររីករាយកើតមានមកកម្ដៅបេះដូងបានមួយគ្រា។ គេនិយាយលលេងបន្តទៀត៖

«ចុះបើអ្នករបួសនៅហ្នឹងរហូត?»

«ហើយមិនទៅដើរសមុទ្រវិញទេ?»

មនុស្សប្រុសមិនដែលដឹងទេថា ពាក្យលេងរបស់ខ្លួនតែងតែធ្វើឱ្យមនុស្សស្រីទុកចិត្ត ហើយគេនិយាយស្រួលៗនៅពេលចិត្តរំភើបរាយមាយ តែគេភ្លេចវិញក៏ងាយដូចគ្នា ធ្វើឱ្យស្រីៗលើផែនដីនេះកើតទុក្ខឈឺចាប់ ព្រោះតែនៅចងចាំពាក្យពេជ្រផ្អែមល្ហែមមួយគ្រានៃពួកកន្លង់។

លើកនេះទៀតសោតLorenzoមិនដឹងថា តើខ្លួនឯងកំពុងធ្វើចិត្តកូននាគ រំភើបអាចនឹងគេងមិនលក់ព្រោះនឹកសម្ដីគេនោះទេ?

គេរឹតតែនិយាយលោនាង៖

«ម៉េចបានស្គាល់ឈ្មោះLorenzo!»

«បងធម៌ខ្ញុំប្រាប់! ហើយនែ៎ បងឯងត្រូវឆាប់ជា បើមិនបានជួបម្នាក់នោះទេ ខ្ញុំត្រូវឡើងទៅភ្នំពេញជួបគេ!»

គេសួរវិញទាំងអស់សំណើច៖

«ហើយទៅរកគេនៅឯណាភ្នំពេញធំយ៉ាងនេះ!»

នាងរអ៊ូ៖

«ទោះពិបាកក៏ត្រូវស៊ូដែរ! ខែប្រាំងជិតចូលមកដល់ហើយ! យើងត្រូវការអណ្ដូងទឹក យើងត្រូវការទឹកមកប្រើ!»

Lorenឈ្ងោកមុខគិត ។ សំឡេងនាងលាន់មកបន្ថែម៖

«ព្រឹកមិញមេឃជិតភ្លៀងកុំអីបានដើរទៅដល់កន្លែងសក្ដិសិទ្ធិដើម្បីបន់ស្រន់ហើយ!»

«ក្រៅពីគេគ្មានអ្នកផ្សេងអាចជីកអណ្ដូងឱ្យបានទេ?»

«មិនមែនងាយទេ! បើសុំពួកបរទេសយើងត្រូវពូកែសរសេរពាក្យសុំ! ហើយភាសាអង់គ្លេសរបស់ខ្ញុំមិនចំណាប់ទេ! សុំខ្មែរដូចគ្នាងាយជាង!»

នាងស្រាប់តែសើចហើយងាកមកនិយាយរឿងផ្សេង៖

«បងឯងនៅតែលើសមុទ្រធ្វើកម្មករគេ អត់ចេះអង់គ្លេសទេមែនអត់? ស្អែកខ្ញុំបង្រៀនក្មេងៗ បងឯងចង់រៀនអត់?»

គេនៅស្ងៀមហើយញញឹមសម្លឹងកូននាគគួរឱ្យស្រលាញ់ នាងនិយាយបន្ទោសតិចៗទៅកាន់កែវភ្នែកផ្អែមល្ហែមរបស់គេ៖

«ស្អែកណា!!!រៀនអត់?»

«រៀនធ្វើអី?»

«រៀន!.....គឺ ចេះតែរៀនទៅ! អូមែន ចាំខ្ញុំបង្កើត Facebook ឱ្យបងឯងមួយទុកឆាតលេងជាមួយគ្នា!»

គេនៅស្ងៀមព្រោះនឹកឃើញដល់រឿងនៅភ្នំពេញ។ ទឹកមុខប្រុសស្អាតប្រែមកជាស្រពោនបោះបង់ចោលមនោសញ្ចេតនាអណ្តែតអណ្តូងក្នុងកែវភ្នែកហើយនៅស្ងៀមឈឹង។

កូននាគតូចរបស់គេចាប់ផ្តើមវាចាសួរ៖

«បងឯងដឹងពាក្យឆាតហ្នឹងមានន័យម៉េចអត់?»

Lorenzo ដៀងភ្នែកមកវិញ ហើយនិយាយមួយៗដាក់នាង៖

«ជួយបងរឿងមួយបានអត់? បងចង់និយាយទូរសព្ទ!»

នាងឃើញគេក្រៀមក្រំ ស្រីតូចដឹងថារឿងដែលគេកំពុងស្នើសុំពិតជាចាំបាច់ណាស់ហើយ។ នាងមិនដឹងធ្វើយ៉ាងណានឹងរកឱ្យ ហើយក៏មិនដឹងថាបដិសេធការស្នើសុំដោយរបៀបណាទៀតដែរ ព្រោះព្រឹកមិញបានប្រាប់រួចហើយថាទីនេះមិនមានសេវា។

សំឡេងបុរសអាណិកជនវាចាមកបន្ថែមផ្ទួនលើចិត្តអន្ទះសាររបស់នាង៖

«ទោះបីត្រូវចេញទៅផ្សារទៅខេត្ត ទៅទីប្រជុំជនណាក៏ដោយ បងចង់ទៅអាឡូវនេះ! បងទៅកើត!»

នាងក្រោកឈរហើយសម្លឹងគេ ធ្វើឱ្យនាយលូកដៃមកបង្វិលរាងកាយតូចចរណៃមកចំពីមុខដោយនិយាយពន្យល់៖

«រឿងចាំបាច់! បងត្រូវការខល! មិនអាចរង់ចាំស្អែកបានទេ!»

ស្រីតូចដកដង្ហើមធំពោលប្រាប់វិញ៖

«ទោះយើងប្រឹងជិះទៅដល់ផ្សារ គេបិទទ្វារគេងលក់អស់មិនខាន! ទូរសព្ទខ្ញុំអត់មានលុយគ្រប់វ៉ៃចេញទេ! មិនអ៊ីចឹង ពេលភ្លឺស្រាងៗខ្ញុំនាំបងឯងទៅ!»

«បងចង់ទៅពេលនេះ! គង់តែអាចរកឃើញអ្នកណាហើយយើងសុំទូរសព្ទគេប្រើបាន! ចុះអ្នកផ្ទះខ្លួនឯង គេមានទូរសព្ទអត់ ! ចង់និយាយថាប៉ាម៉ាក់អីហ្នឹងណ៎ា!»

នាងលែងមាត់ តែងាកទៅរកមើលម៉ូតូ។

បុរសដឹងថា គេអាចចេញទៅទីប្រជុំជនបាន ហើយចំណែកពេលថ្មើរណេះគ្មានអ្នកណាចូលមកម្ដុំនេះរកមើលពួកគេទេ។

ទីបំផុតនាងបានប្ដូរអាវចាស់ដែលដាច់ដៃម្ខាងរបស់គេនោះចេញ ហើយឱ្យអាវយឺតធំរលង់ មានរូបគណបក្សនយោបាយឲ្យគេពាក់។

«សំណាងហើយបងឯង! កាលពីគេចុះឃោសនាបោះឆ្នោតឃុំ ខ្ញុំបានអាវនេះពីរបីយកមកទុកក្រែងមានអ្នកណាខ្វះអាវពាក់ខែរងា!»

«គិតវែងឆ្ងាយដូចមនុស្សចាស់!»

អ្នកមានដូចគេនេះ មិនដែលដឹងទេថាអ្នកក្រខ្វះមុខ ខ្វះក្រោយគិតបែបណាសន្សំសំចៃកម្រិតណា ហើយរស់ដោយរបៀបណា?

ហើយនេះក៏ជារឿងដ៏គួរឱ្យភ្ញាក់ផ្អើលមួយទៀតដែរ ព្រោះគេមិនដែលគិតទុកមកទេថា មានថ្ងៃមកជិះម៉ូតូចាស់លាន់ម៉ាស៊ីនធំប្រេងកម្រិតនេះ ហើយជាមួយនារីម្នាក់នេះ ក្នុងចម្ងាយផ្លូវរាប់គីឡូនាពេលវេលាថ្មើរណេះ?

គេសួរខ្លួនឯង តើឯងជិះម៉ូតូចុងក្រោយបង្អស់កាលពីឆ្នាំណាទៅ? ត្រូវហើយនឹកមិនឃើញទេ!មិនដែលជិះទេ តាមថា! អូមែនហើយជិះចុងក្រោយកាលពីយប់មិញហ្នឹងឯង គឺជិះពីក្រោយនាងបានបន្តិច ក៏រលត់ស្មារតីសន្លប់ឈឹងបាត់ព្រោះតែការឡើងកម្ដៅ។

«អ្ហ៎ !»

គេហៅនាងព្ញៗ ព្រោះនាងពាក់មួក គេក៏ពាក់មួកម៉ូតូដ៏ធំហើយធ្ងន់។

«មានការអី?»

គេដោះមួកមកកាន់ហើយនិយាយៈ

«ប៉ិនម៉េះ? យប់មិញឱបមនុស្សសន្លប់មួយបាន? ផ្លូវមហារលាក់?»

«បងឯងត្រូវដឹងគុណខ្ញុំហើយអ៊ីចឹង!»

នាងនិយាយកំប្លែងតែចិត្តនាយចាប់អាណោចអនេក។

ចេញពីផ្ទះអនាគតមកគេមិនដែលគិតថានឹងមានថ្ងៃព្រមវិលទៅផ្ទះអនាគតវិញជាដាច់ខាត គេនឹងទាក់ទងជំនួយការព្រមទាំងរកវិធីចេញទៅរកទីសុវត្ថិភាពជាមួយពួកគេវិញ។

«រីករាយណាស់ដែលបានស្គាល់កូននាគតូច!»

គេគិតស្ងាត់ៗក្នុងចិត្ត ទាំងញញឹមលាយក្ដីអាឡោះ។ ស្រាប់តែ នាងនិយាយទៀតៈ

«ខ្ញុំមិនទារគុណអីទាំងអស់ ព្រោះបងឯងក៏អ្នកអត់ខ្ញុំដឹងហើយ មិនបាច់អង្គុយពិបាកចិត្តទេ!»

ដោយសារនាងខំនិយាយប្រណាំងកម្លាំងខ្យល់ទើបសំឡេងនាងខ្លាំងៗហើយស្រួយស្រឹប។

សរសៃសក់នាងប៉ោងមកតាមខ្យល់ប៉ះនាសានាយក្រអូបក្លិនក្រូចប្រហើរៗមិនដែលមានអារម្មណ៍ធម្មជាតិបែបនេះពីមុនមកឡើយ។

«បានអីមកលាបសក់ក្រអូបម្ល៉េះកូននាគ?»

«ព្រឹកមិញទៅព្រៃបងឯងមិនឃើញខ្ញុំបេះស្លឹកក្រូចសើចទេ?»

«អាចធ្វើជាសាប៊ូ?»

«បាន! អ្នកណាថាមិនបាន?»

«ហើយចុះមានច្រើនអត់ដើមក្រូចអស់ហ្នឹង!»

«ច្រើនណាស់បងឯងមិនសម្គាល់មើល?»

«អ៊ីចឹងមិនបើករោងចក្រធ្វើសាប៊ូមួយហ្មងទៅ! ឱ្យអ្នកព្រៃភ្នំទាំងអស់បានការងារធ្វើផង នឹងអាលឈប់ញ៉ាំអាឆែថាវ ធុំក្លិនអាក្រក់អស់ទាំងហ្នឹង?»

«ប្រាប់ហើយថាឆៃប៉ូវ!»

«ដូចតែគ្នាហ្នឹងហៅអាម៉េចក៏វាដូចតែគ្នា!»

«ឆែថាវញ៉ាំនៅមិនបានទេ! តែឆៃប៉ូវញ៉ាំបាន!»

«ឈប់និយាយទៅតិចបងដូរឈ្មោះខ្លួនឯងមកជាកញ្ញាឆៃថាវអាឡូវហ្នឹងហើយ!»

នាងបិទមាត់។ គេដឹងហើយថា នាងចូលចិត្តឈ្មោះ«កូននាគ»តែមិនចង់បាននាមកញ្ញាឆៃថាវទេ។ គេនិយាយបន្ទប់ទៅរឿងដដែលៈ

«ឮបងនិយាយអត់? បើករោងចក្រធ្វើសាប៊ូមួយហ្មងទៅ! ឱ្យអ្នកព្រៃភ្នំទាំងអស់បានការងារធ្វើផង!»

«ហ្នឹងហើយ! បងឯងនិយាយធ្វើមើលតែខ្លួនឯងជាអ្នករកស៊ី!»

គេដល់ពេលស្ងាត់មាត់ទៀតហើយ។ ឱ្យតែត្រូវនាងរំឭកដល់សមាសភាពរបស់គេម្តងៗ ភាពប្រឆាំងគ្នារវាងLorenzoនិងកម្មករនេសាទ ចេះតែបង្ខំគេឱ្យក្រៀមក្រំ។ កើតមកជាកម្មករនេសាទក៏មិនមែនថាមិនល្អទាំងស្រុងដែរ ហោចណាស់មានស្រីម្នាក់ថៃទាំយើងអត់ដេកពួនពេញមួយយប់។ ចំណែក Lorenzoបានត្រឹមតែសម្រាប់ឱ្យគេសុំអណ្តូងទឹកប៉ុណ្ណឹងឬអ្វី?

នេះហើយជាមូលហេតុដែលគេមិនដែលរកបានម្ចាស់ចិត្តណាម្នាក់ឱ្យពិតប្រាកដតាំងពីអាមេរិករហូតដល់ស្រុកខ្មែរ។ ស្រីៗផ្អើលចង់ជួបទេវបុត្រ Lorenzo ព្រោះតែភាពសប្បុរសនិងធនធានមហាសាលរបស់គេ?

«ចាំរួចរាល់ហើយ បងឯងត្រូវរៀនលេងឆាត! ហើយឆាតមកខ្ញុំ! ខ្ញុំខានទៅសមុទ្រជិត៥ឆ្នាំហើយ ខេត្តកោះកុងនៅជិតបង្កើយខ្ញុំមិនដែលបានឃើញសមុទ្រសោះ នឹកណាស់!»

ឮហើយ គេពិតជាចង់ឱបចង្កេះកូននាគតូចរត់ប្រដេញគ្នាលើឆ្នេរ ឬក៏យប់អធ្រាត្រឡើងកាលណាបណ្តើរគ្នាទៅរកមើលពពុះសមុទ្រដូចគូស្នេហ៍ក្នុងរឿងនិទានអាស៊ីល្បីៗដែលគេធ្លាប់អាននិងបឋមវ័យ។

ទំនាក់ទំនងជាវសៀវភៅ ០១៥២១៣១១១